# ការរង់ចាំ និង សកម្មភាព

ខ្មែរ សករណីយ[1] ដែល ជា អ្នកតស៊ូ ដើម្បី ប្រជាធិបតី និង សេរីភាព គប្បី មាន សង្វរ[2] មិនយក ការរង់ចាំ ធ្វើ ជា សកម្មភាព សំរាប់ ការតស៊ូ ព្រោះ នាំឱ្យ ចិត្ត សង្រេក បើ ការរំពឹងទុក នេះ វា អាស្រ័យ លើ អ្នកដទៃ។ មិនដូច សកម្មភាព សន្ទិដ្ឋិក[3] គឺ ទុក ខ្លួនឯង ជា ម្ចាស់ នៃ ការតស៊ូ ជា គោលការណ៏ វា នាំអោយ មាន សន្ដោស ជា កម្លាំងបង្កប់ នៅក្នុង ចិត្ត ហើយ អាច ស្គាល់ អ្វី ដែល ជា ចំណុច ខ្លាំង និង អ្វី ដែល ជា ចំណុច ខ្សោយ របស់ ខ្លួន ដោយ ខ្លួនឯង។ រង់ចាំ រំពឹង តែ ជំនួយ និង កម្លាំង អន្តរជាតិ គឺ អន្ទោល ស្លាប់រស់ ក្នុង ដង្ហើម របស់អ្នកដទៃ។ ទីទៃពី សកម្មភាព ដែល មាន ការរៀបចំ ដោយ ខ្លួនឯង ហើយ រក បំណះ[4] អោយ ស្មើគ្នានឹង កម្លាំង អន្តរជាតិ ដែល គេ ចង់ជួយ វា នាំឱ្យ មើល ទៅឃើញ ត្រឡង[5] គោលដៅ នៅទី បញ្ចប់ ជា និច្ច នៅក្នុង ដំណើរ នៃ ការតស៊ូ។ រីសកម្មភាព វា ជា ចំណី សំរាប់ កម្លាំង កាយ និង បញ្ញា ដែល បង្កើត ក្ដីសង្ឃឹម សកម្ម។ តែ សកម្មភាព ត្រូវ មាន ភាពមោះមុត និង ការភ្នាល់ចិត្ត (défi)

---

[1] សករណីយ (បើស្ត្រី សករណីយា) : ន. អ្នកដែលមានកិច្ចការត្រូវធ្វើ។
[2] សង្វរ : ន. ការសង្រួម បិទ ឬ ប្រយ័ត្នមិនអោយអារម្មណ៏អាក្រក់ចូលក្នុងចិត្តបាន។
[3] សន្ទិដ្ឋិក (សន់ ទិត ឋិ កៈ) : គុ. ដែលឃើញខ្លួន។ សន្ទិដ្ឋិកហេតុ, ដំណើរដែលជាក់ប្រាកដផ្ទាល់ខ្លួន។
[4] បំណះ : គូដែលប៉ះគ្នា។
[5] ត្រឡង : ដែលភ្លឺមូល, ពន្លឺ នៃ ចង្កៀងបញ្ចាំង (Phare)។

# ការរង់ចាំ និង សកម្មភាព

នៅ ចំពោះមុខ ឧបសគ្គ និង មារ គ្រប់ បែបយ៉ាង ដូច ពួក បូជនីយេសក៏ (pèlerin) នាំគ្នា ស្វះស្វែង រក ទីកន្លែង ដែល គួរគោរព។ ចំពោះ អ្នកតស៊ូ ទីកន្លែង នោះ គឺ លទ្ធិប្រជាធិបតេយ្យ សេរី និង សេរីភាព។ ជំនឿ ដែល អ្នកតស៊ូ មាន រួចស្រេច គឺ គ្មាន កម្លាំង អ្វីមួយ អាច ប្រយុទ្ធ យកឈ្នះនឹង ចំណង់ នៃ សេរីភាព របស់ មនុស្សលោក នោះបានឡើយ ព្រោះ សេរីភាព ជា បំណាច់ របស់ ធម្មជាតិ នៃ ជាតិមនុស្ស។ រី ការរង់ចាំ នាំបង្កើត ជា រឿយៗ នូវ បំណាំ ដែល ជា ប្រភព នៃ ជម្លោះ រវាង អ្នកអកម្ម ព្រោះ គិតតែ ប្រចាំគ្នា ធ្វើ អ្វីមួយ។ មួយវិញទៀត វា មិន បំបាន នូវ សាមគ្គីភាព និង បំបាក់បំបប វិន័យ នៃ ការតស៊ូ ដែល នាំ បំបែរ ចិត្ត ទៅរក ការអស់សង្ឃឹម និង ធ្វើអោយ ចលនា តស៊ូ បែក ជា បំណែក ខ្ចាត់ចេញពីគ្នា បាន ងាយស្រួល។ ដូច្នេះ ការរង់ចាំ ជា ផ្លូវទាល់, ទីទៃពី សកម្មភាព ជា មហាវិថី នៃ ជោគជ័យ របស់ អ្នកតស៊ូ ដើម្បី សេរីភាព និង លទ្ធិប្រជាធិបតេយ្យ សេរី។

សំនួរ សួរ ថា តើ ប្រជាពលរដ្ឋខ្មែរ សព្វថ្ងៃ មាន ចំណង់ នៃ សេរីភាព ដែរឬទេ ? តើ អ្នកប្រជាធិបតេយ្យខ្មែរ ហ៊ាន ភ្ជាល់ចិត្ត បន្ត ប្រទល់មុខនឹង អំណាច ផ្តាច់ការ ដែរឬទេ ?